DEPARTMENT OF HEALTH

# ច្បាប់ស្តីពីសិទ្ធិការថែទាំតាមគេហដ្ឋានរបស់សហព័ន្ធ និង រដ្ឋរួមបញ្ចូលគ្នាសម្រាប់អតិថិជនរស់នៅដោយត្រូវការជំនួយ សេចក្តីថ្លែងការណ៍អំពីសិទ្ធិ

អតិថិជន ដែលទទួលបានសេវាថែទាំតាមផ្ទះ នៅក្នុងសហគមន៍ រស់នៅ ដែលទទួលបានជំនួយ គឺមានសិទ្ធិបីយ៉ាង ហើយ ក្រុមហ៊ុនផ្តល់សេវាត្រូវតែផ្តល់នូវសិទ្ធិដូចខាងក្រោមនេះ៖

*អ្នកផ្តល់សេវាមានន័យថាភ្នាក់ងារសុខភាពតាមផ្ទះដែលមានវិញ្ញាបនបត្រមេឌីឃារ (HHA)

*អតិថិជនមានន័យថា អ្នកជំងឺ

1. **អ្នកផ្តល់សេវាត្រូវតែផ្តល់ព័ត៌មាន ដែលបានសរសេរឡើង** ជាភាសាសាមញ្ញ **អំពីសិទ្ធិក្នុងកំលុងពេលមកមើលជាលើកដំបូង អ្នកផ្តល់សេវា ដែលផ្តល់ការថែទាំដល់អតិថិជនជាមុន។ សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវតែមានលក្ខណៈអាចងាយយល់បានចំពោះអ្នក ដែលនិយាយភាសាអង់គ្លេសនៅមានកម្រិតទាប និង អាចប្រើប្រាស់បានចំពោះជនពិការម្នាក់ៗ** រួមទាំងអ្វីៗដែលត្រូវធ្វើ ប្រសិនបើសិទ្ធិរបស់គេត្រូវបានរំលោភបំពាន។
2. **អ្នកផ្តល់សេវាត្រូវតែផ្តល់ព័ត៌មានទំនាក់ទំនងរបស់អ្នកគ្រប់គ្រងនៃអ្នកផ្តល់សេវា រួមទាំងឈ្មោះអ្នកគ្រប់គ្រង អាសយដ្ឋាន និង លេខទូរសព្ទអាជីវកម្ម ដើម្បីទទួលពាក្យបណ្តឹងតវ៉ា។**
3. **អ្នកផ្តល់សេវាត្រូវតែការជូនដំណឹងដោយផ្ទាល់មាត់អំពីសិទ្ធិ និង ការទទួលខុសត្រូវនានារបស់អតិថិជនជាភាសាចម្បង ឬ ភាសា ដែលពួកគេចង់បាន និង តាមរបៀប ដែលបុគ្គលម្នាក់ៗយល់ ដោយឥតគិតថ្លៃ ដោយប្រើអ្នកបកប្រែភាសា ដែលមានសមត្ថភាព ប្រសិនបើចាំបាច់។**
4. ទទួលការថែទាំ និង សេវានានា ដោយផ្អែកទៅតាមផែនការដែលសមស្រប និង ទាន់សម័យ និង ដោយផ្អែកទៅលើការថែទាំសុខភាព ដែលបានទទួលយកបានតាមស្តង់ដារវេជ្ជសាស្រ្ត ឬ គិលានុបដ្ឋាយិកា និង ការថែទាំ ដោយយកចិត្តទុកដាក់លើមនុស្ស ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍ ការកែប្រែ និង ការវាយតម្លៃទៅលើផែនការ និង សេវានានា។
5. ត្រូវប្រាប់ទៅដល់អតិថិជន មុនពេលទទួលសេវា និង អំពីសិទ្ធិ**ចូលរួម ។ ត្រូវណែនាំអំពីការថែទាំ និង ការយល់ព្រម ឬ ការបដិសេធចំពោះការថែទាំទៅដល់អតិថិជនជាមុន និង នៅក្នុងកំលុងពេលនៃការព្យាបាល ដោយគោរពទៅតាម៖**
    - ជម្រើសផ្សេងទៀត ដែលមានសម្រាប់ការដោះស្រាយទៅលើតម្រូវការថែទាំតាមផ្ទះ និង ផលវិបាក ដែលអាចកើតមាន ចំពោះការបដិសេធលើសេវាទាំងអស់នេះ។
    - **ការបញ្ចប់ការវាយតម្លៃទាំងអស់។**
    - **ការថែទាំ ដែលបានផ្តល់ ដោយផ្អែកទៅលើការវាយតម្លៃដ៏ទូលំទូលាយ។**
    - **ការបង្កើត និង ការកែប្រែផែនការថែទាំ។**
    - **វិន័យ ដែលនឹងផ្តល់ការយកចិត្តទុកដាក់ដល់ការថែទាំ។**
    - **ភាពញឹកញាប់នៃការមកមើល។**
    - **លទ្ធផលរំពឹងទុកនៃការថែទាំ រួមបញ្ចូលទាំងគោលដៅ ដែលបានកំណត់ទៅលើអតិថិជន និង ហានិភ័យ និង អត្ថប្រយោជន៍នានា ដែលបានប៉ាន់ស្មានទុក។**
    - **រាល់កត្តានានាណាមួយ ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការព្យាបាល។**
    - រាល់ការផ្លាស់ប្តូរនានាណាមួយនៅក្នុងការថែទាំ ដែលបានផ្តល់ជូន។

6. ត្រូវប្រាប់ជាមុនអំពីការផ្លាស់ប្តូរ ដែលបានណែនាំ ដោយអ្នកផ្តល់សេវានៅក្នុងផែនការសេវា និង ការចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការសម្រេចចិត្តអំពីការផ្លាស់ប្តូរផែនការសេវា។

**7. ទទួលបានសេវាទាំងអស់ ដែលមានចែងក្នុងផែនការថែទាំ។**

**8.** បដិសេធទៅលើសេវា ឬ ការព្យាបាល។

9. ត្រូវដឹង មុនពេលទទួលបានសេវា ឬ ក្នុងកំលុងពេលមកជួបលើកដំបូង រាល់កម្រិតណាមួយ ចំពោះសេវា ដែលមានផ្តល់ជូន ដោយអ្នកផ្តល់សេវាថែទាំតាមផ្ទះ។

**10.** ត្រូវប្រាប់ជាមុន នៅមុនពេលសេវានឹងត្រូវបានផ្តួចផ្តើម ចំពោះអ្វី ដែលអ្នកផ្តល់សេវាគិតថ្លៃសម្រាប់សេវាត្រូវប្រាប់អតិថិជន។ តើការបង់ប្រាក់ធានារ៉ាប់រងកម្រិតណា ដែលអាចទទួលបានពីការធានារ៉ាប់រងសុខភាព កម្មវិធីសាធារណៈ ឬ ប្រភពផ្សេងៗទៀត រួមបញ្ចូលទាំង **មេឌីឃែរ និង មេឌីខេដ ឬ កម្មវិធី ដែលផ្តល់ថវិកាដោយសហព័ន្ធ ឬ កម្មវិធីជំនួយសហព័ន្ធ ដែលត្រូវបានស្គាល់ ដោយអ្នកផ្តល់សេវា** ប្រសិនបើគេស្គាល់។ តើការចំណាយអ្វីខ្លះ ដែលអតិថិជនអាចទទួលខុសត្រូវចំពោះការបង់ប្រាក់និង **ការផ្លាស់ប្តូរណាមួយ** អំពីព័ត៌មានការបង់ប្រាក់**ឱ្យបានឆាប់តាម ដែលអាចធ្វើទៅបាន មុនការមកជួបអ្នកផ្តល់សេវាបន្ទាប់។**

11. ដឹងថា អាចមានសេវាផ្សេងទៀត ដែលដំណើរការនៅក្នុងសហគមន៍រួមទាំងសេវា និង អ្នកផ្តល់សេវាថែទាំតាមផ្ទះផ្សេងទៀត និង ត្រូវដឹងពីកន្លែង ដែលត្រូវស្វែងរកព័ត៌មានអំពីសេវាទាំងនេះ។

12. ជ្រើសរើសដោយសេរីក្នុងចំណោមអ្នកផ្តល់សេវាដែលមាន និង ផ្លាស់ប្តូរអ្នកផ្តល់សេវាបន្ទាប់ពីសេវាបានចាប់ផ្តើមហើយ នៅក្នុងកម្រិតនៃការធានារ៉ាប់រងសុខភាព ការធានារ៉ាប់រងការថែទាំរយៈពេលវែង ជំនួយវេជ្ជសាស្ត្រ ឬ កម្មវិធីសុខភាពផ្សេងទៀត ឬ ក៏កម្មវិធីសាធារណៈផ្សេងៗ។

**13.** ព័ត៌មានផ្ទាល់ខ្លួន ហិរញ្ញវត្ថុ និង វេជ្ជសាស្ត្រត្រូវបានរក្សាជាឯកជន ហើយត្រូវទទួលបានការណែនាំពីគោលការណ៍ និង នីតិវិធីរបស់អ្នកផ្តល់សេវាទាក់ទងនឹងការបង្ហាញព័ត៌មានបែបនេះ **ដោយរាប់បញ្ចូលនូវសេចក្តីជូនដំណឹងឯកជនភាពកំណត់ព័ត៌មានលទ្ធផល និង ការវាយតម្លៃ (OASIS) សម្រាប់អតិថិជនទាំងអស់ ដែលទិន្នន័យ OASIS របស់ខ្លួន ត្រូវបានប្រមូល។**

14. ចូលមើលកំណត់ត្រាផ្ទាល់ខ្លួនរបស់អតិថិជន និង ព័ត៌មានជាលាយលក្ខណ៍អក្សរ ចេញពី កំណត់ត្រាទាំងនោះ ដោយអនុលោមទៅតាមច្បាប់កំណត់ត្រាសុខភាពរបស់រដ្ឋមីនីសូតា (Minnesota) រដ្ឋធម្មនុញ្ញរដ្ឋមីនីសូតា មាត្រា 144.291 ដល់ 144.298។

15. ត្រូវបានបម្រើសេវាថែទាំ ដោយអ្នក ដែលទទួលការបណ្តុះបណ្តាលត្រឹមត្រូវ និង មានសមត្ថភាពបំពេញភារកិច្ចរបស់ខ្លួន។

16. ត្រូវបានប្រព្រឹត្តដាក់ដោយចេះគួរសម និង ការគោរព និង គោរពថែរក្សាទ្រព្យសម្បត្តិរបស់អតិថិជន។

17. រួចផុតពីការរំលោភបំពានដោយពាក្យសំដី **លើផ្លូវចិត្ត ផ្លូវភេទ** និង ការរំលោភបំពានលើរាងកាយ **រួមទាំងការរងរបួសដោយប្រភពមិនស្គាល់** ការធ្វេសប្រហែស ការកេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុ/**ការប្រើប្រាស់ទ្រព្យមិនត្រឹមត្រូវ** និង គ្រប់ទម្រង់ទាំងអស់នៃការធ្វើទុក្ខទោស ដែលស្ថិតនៅក្រោមច្បាប់មនុស្សពេញវ័យ ដែលងាយរងគ្រោះ និង ការរំលោភបំពានលើអនីតិជន។

**18.** ការជូនដំណឹងជាមុន ដែលសមហេតុផលអំពីការផ្លាស់ប្តូរសេវា ឬ ថ្លៃសេវា **មុនពេលផ្តល់សេវាជាក់លាក់ណាមួយ ដែលបានផ្តល់ជូន ប្រសិនបើអ្នកផ្តល់សេវាជឿថា សេវានោះអាចជាការថែទាំ ដែលមិនមានការធានាចេញថ្លៃ ឬ មុនពេលអ្នកផ្តល់សេវាកាត់បន្ថយ ឬ បញ្ឈប់ការផ្តល់សេវាជាប្រចាំ។**

19. ដឹងពីហេតុផលរបស់អ្នកផ្តល់សេវាក្នុងការបញ្ចប់សេវា។

**20.** ត្រូវបានជូនដំណឹងអំពីគោលការណ៍ និង នីតិវិធីរបស់អ្នកផ្តល់សេវាសម្រាប់ការផ្ទេរចេញ និង ការបញ្ជូនចេញ (ពីមណ្ឌលថែទាំ) នៅក្នុងភាសាមួយ ដែលអតិថិជនអាចយល់បាន និង អាចចូលប្រើប្រាស់បានចំពោះជនពិការក្នុងរយៈពេល 4 ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការចុះវាយតម្លៃដំបូង។ អ្នកផ្តល់សេវាអាចផ្ទេរចេញ ឬ ឲ្យអតិថិជនចេញបានលុះត្រាតែ៖

- ការផ្ទេរ ឬ ការបញ្ជូនចេញ (ពីកន្លែងថែទាំ) គឺចាំបាច់សម្រាប់សុខុមាលភាពរបស់អតិថិជន ពីព្រោះអ្នកផ្តល់សេវា និង គ្រូពេទ្យ ដែលទទួលខុសត្រូវចំពោះផែនការថែទាំយល់ស្របថា អ្នកផ្តល់សេវាមិនអាចបំពេញតម្រូវការរបស់អតិថិជនបានទៀតទេ ដោយផ្អែកលើភាពធ្ងន់ធ្ងររបស់អតិថិជន។ អ្នកផ្តល់សេវាត្រូវតែរៀបចំការផ្ទេរចេញ ដោយសុវត្ថិភាព និង សមរម្យទៅអង្គការថែទាំផ្សេងទៀតនៅពេលដែលតម្រូវការរបស់អតិថិជន គឺហួសពីសមត្ថភាពរបស់អ្នកផ្តល់សេវា។
- អតិថិជន ឬ អ្នកបង់ប្រាក់នឹងមិនបង់ថ្លៃសេវា ដែលបានផ្តល់ជូនទៀតទេ។
- ការផ្ទេរចេញ ឬ ការបញ្ជូនចេញ (ពីកន្លែងថែទាំ) គឺសមរម្យត្រឹមត្រូវ ពីព្រោះគ្រូពេទ្យ ដែលទទួលខុសត្រូវផែនការថែទាំ និង អ្នកផ្តល់សេវាថែទាំយល់ស្របថាលទ្ធផល និង គោលដៅ ដែលបានចែងក្នុងផែនការថែទាំត្រូវបានសម្រេច ហើយអ្នកផ្តល់សេវាថែទាំ និង គ្រូពេទ្យ ដែលទទួលខុសត្រូវចំពោះផែនការថែទាំយល់ស្របថា អតិថិជន គឺពិតជាលែងត្រូវការសេវាទៀតហើយ។
- អតិថិជនបដិសេធសេវា ឬ ជ្រើសរើសការផ្ទេរចេញ ឬ ការបញ្ជូនចេញ (ពីកន្លែងថែទាំ)។
- អ្នកផ្តល់សេវាកំណត់តាមគោលការណ៍ ដែលបានចែង ដោយអ្នកផ្តល់សេវាខ្លួនឯងក្នុងគោលបំណងដោះស្រាយការបញ្ជូនចេញ (ពីកន្លែងថែទាំ) ដោយមានមូលហេតុ ដែលបំពេញតាមលក្ខខណ្ឌនៃមាត្រានេះ ដែលថាអតិថិជន (ឬ មនុស្សផ្សេងទៀតនៅក្នុងផ្ទះរបស់អតិថិជន) មានអាកប្បកិរិយារំខាន ការរំលោភបំពាន ឬ ការមិនសហការដល់កម្រិតមួយ ដែលថា ការផ្តល់ការថែទាំដល់អតិថិជន ឬ សមត្ថភាពរបស់អ្នកផ្តល់សេវា ដើម្បីប្រតិបត្តិការប្រកប ដោយប្រសិទ្ធភាពនោះ គឺអនុវត្តទៅពុំមានប្រសិទ្ធិភាព។ អ្នកផ្តល់សេវាត្រូវធ្វើដូចតទៅនេះមុនពេលខ្លួនឲ្យអតិថិជនការបញ្ជូនចេញ (ពីកន្លែងថែទាំ) ដោយមានមូលហេតុ៖
    - ណែនាំដល់អតិថិជន អ្នកតំណាង (ប្រសិនបើមាន) គ្រូពេទ្យ ដែលចេញវេជ្ជបញ្ជាសម្រាប់ផែនការថែទាំ និង អ្នកថែទាំបឋមរបស់អតិថិជន ឬ អ្នកជំនាញថែទាំសុខភាពផ្សេងទៀត ដែលនឹងទទួលខុសត្រូវក្នុងការផ្តល់ការថែទាំ និង សេវាដល់អតិថិជន បន្ទាប់ពីបានចាកចេញពីអ្នកផ្តល់សេវា (ប្រសិនបើមាន) ដោយប្រាប់ថា ការឲ្យចាកចេញ ដោយមានមូលហេតុ គឺកំពុងតែត្រូវបានពិចារណា។
    - ខិតខំប្រឹងប្រែងដោះស្រាយបញ្ហា ដែលបង្កឡើង ដោយឥរិយាបទរបស់អតិថិជន ឥរិយាបទរបស់មនុស្សផ្សេងទៀត នៅក្នុងផ្ទះរបស់អតិថិជន ឬ ដោយស្ថានភាពណាមួយ។
    - ផ្តល់ជូនអតិថិជន និង អ្នកតំណាង (ប្រសិនបើមាន) នូវព័ត៌មានទំនាក់ទំនងសម្រាប់ទីភ្នាក់ងារ ឬ អ្នកផ្តល់សេវាផ្សេងទៀត ដែលអាចផ្តល់ការថែទាំបាន។
    - ចងក្រងឯកសារអំពីបញ្ហា និង ការខិតខំប្រឹងប្រែង ដែលបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហា ហើយបញ្ចូលឯកសារនេះទៅក្នុងកំណត់ត្រាគ្លីនិក។
- អតិថិជនបានស្លាប់។
- ទីភ្នាក់ងារអ្នកផ្តល់សេវាបានឈប់ដំណើរការ។

21. ការជូនដំណឹងជាមុនយ៉ាងតិច 30 ថ្ងៃអំពីការបញ្ចប់សេវា ដោយអ្នកផ្តល់សេវាលើកលែងតែក្នុងករណីដែលមាន៖

- អ្នកទទួលសេវាចូលរួមក្នុងការប្រព្រឹត្តដែលផ្លាស់ប្តូរលក្ខខណ្ឌការងារ ដូចមានចែងក្នុងកិច្ចសន្យាការងាររវាងអ្នកផ្តល់សេវាថែទាំតាមផ្ទះ និង បុគ្គល ដែលផ្តល់សេវាថែទាំតាមផ្ទះ ឬ បង្កើតបរិយាកាសការងារ ដែលរំលោភបំពាន ឬ មិនមានសុវត្ថិភាពសម្រាប់បុគ្គល ដែលផ្តល់សេវាថែទាំតាមផ្ទះនោះ។

- ភាពអាសន្នសម្រាប់អ្នកថែទាំក្រៅផ្លូវការ ឬ ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងស្ថានភាពរបស់អ្នកទទួលការថែទាំបានបណ្តាលឱ្យមានតម្រូវការសេវា ដែលលើសពីកិច្ចព្រមព្រៀងរបស់អ្នកផ្តល់សេវាបច្ចុប្បន្ន ហើយដែលមិនអាចផ្តល់ឱ្យដោយអ្នកផ្តល់សេវាថែទាំតាមផ្ទះដោយសុវត្ថិភាពបាន។ ឬ
- អ្នកផ្តល់សេវាមិនបានទទួលការបង់ប្រាក់សម្រាប់សេវា ដែលសេចក្តីជូនដំណឹងយ៉ាងហោចណាស់ឲ្យបានដប់ថ្ងៃជាមុនអំពីការបញ្ចប់សេវានឹងត្រូវបានផ្តល់ជូន។

22. ការផ្ទេរចេញដោយមានការសំរបសំរួលនៅពេលមានការផ្លាស់ប្តូរអ្នកផ្តល់សេវា។
23. បណ្តឹងតវ៉ាទៅកាន់បុគ្គលិកនិងអ្នកដទៃទៀតអំពីជម្រើសរបស់អតិថិជនសម្រាប់សេវា, **ការព្យាបាល ឬ ការថែទាំ** ដែលបានផ្តល់ជូន ឬ ខកខានមិនបានផ្តល់ជូន និង កង្វះសុជីវធម៌ ឬ ការគោរពចំពោះអតិថិជន ឬ ទ្រព្យសម្បត្តិរបស់អតិថិជន និង សិទ្ធិក្នុងការផ្តល់យោបល់អំពីការផ្លាស់ប្តូរគោលការណ៍ និង សេវាដោយមិនមានការសងសឹក រួមទាំងការគំរាមកំហែងនៃការបញ្ឈប់សេវា។ **សិទ្ធិត្រូវបានណែនាំពី** មជ្ឈមណ្ឌលរាយការណ៍អំពីការរំលោភបំពានមនុស្សពេញវ័យ MN (MAARC), **ដែលគោលបំណងរបស់វាគឺដើម្បីទទួលយកពាក្យបណ្តឹងតវ៉ា និងខ្សែទូរសព្ទសុខភាពតាមផ្ទះ ដោយឥតគិតថ្លៃរបស់រដ្ឋ ព័ត៌មានទំនាក់ទំនងរបស់វា ពេលវេលាប្រតិបត្តិការសម្រាប់សួរសំណួរអំពីអ្នកផ្តល់សេវាក្នុងស្រុក។**
24. ដឹងពីវិធីទាក់ទងបុគ្គល ដែលមានទំនាក់ទំនងជាមួយអ្នកផ្តល់សេវាថែទាំតាមផ្ទះដែលទទួលខុសត្រូវក្នុងការដោះស្រាយបញ្ហា និង អនុញ្ញាតឱ្យអ្នកផ្តល់សេវាថែទាំតាមផ្ទះធ្វើការស៊ើបអង្កេត និង ព្យាយាមដោះស្រាយបណ្តឹងសារទុក្ខ។
25. ស្គាល់ឈ្មោះ និង អាសយដ្ឋាន និង លេខទូរសព្ទរបស់ទីភ្នាក់ងាររដ្ឋ ឬ ខោនធីដើម្បីទាក់ទងសាកសួរព័ត៌មាន ឬ ជំនួយបន្ថែម **ហើយប្រសិនបើអាច គឺសាកសួរពីអង្គការ ដែលមានមូលនិធិសហព័ន្ធ ដែលបម្រើក្នុងតំបន់ ដែលអតិថិជនរស់នៅ។**
26. អះអាងអំពីសិទ្ធិទាំងនេះដោយផ្ទាល់ ឬ អនុញ្ញាតឲ្យមានការអះអាងដោយតំណាងរបស់អតិថិជន ឬ ដោយនរណាម្នាក់ក្នុងនាមអតិថិជន ដោយមិនមានការសងសឹក **និង រួចផុតពីការរើសអើង ឬ ការសងសឹកចំពោះការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបង្ហាញនូវការតវ៉ាចំពោះអ្នកផ្តល់សេវា ឬ អង្គការខាងក្រៅ។**
27. **ត្រូវបានជូនដំណឹងអំពីសិទ្ធិក្នុងការទទួលបានជំនួយបន្ថែម និង សេវាជំនួយខាងភាសា និង វិធីដើម្បីទទួលបានសេវាទាំងនេះ។**
28. ដាក់ឧបករណ៍ត្រួតពិនិត្យអេឡិចត្រូនិចនៅក្នុងកន្លែងរបស់អតិថិជន ឬ អ្នករស់នៅដោយគោរពទៅតាមលក្ខខណ្ឌរបស់រដ្ឋ។

អ្នកអាចជ្រើសរើសពិភាក្សាអំពីកង្វល់ណាមួយជាមួយនឹងអ្នកផ្តល់សេវារបស់អ្នក។ ជាការរំលឹក អ្នកផ្តល់សេវា គឺត្រូវបានតម្រូវឲ្យធ្វើការយ៉ាងណា ដើម្បីធានាអំពីសិទ្ធិរបស់អ្នក ហើយតម្រូវការផ្សេងទៀតត្រូវបានអនុវត្តតាមផងដែរ។ នៅពេលអ្នកផ្តល់សេវារំលោភបំពានទៅលើសិទ្ធិនៅក្នុងមាត្រានេះ ពួកគេត្រូវទទួលការពិន័យ និង ការចាត់វិធានការ ផ្នែកអាជ្ញាប័ណ្ណ។

អ្នកផ្តល់សេវាត្រូវធ្វើដូចខាងក្រោម៖

- លើកទឹកចិត្ត និង ជួយក្នុងការអនុវត្តសិទ្ធិទាំងនេះឱ្យបានពេញលេញ។
- ផ្តល់ឈ្មោះ និង លេខទូរសព្ទរបស់បុគ្គល និង អង្គការ ដែលផ្តល់ការតស៊ូមតិនិង សេវាផ្លូវច្បាប់សម្រាប់អតិថិជន និង ប្រជាជនក្នុងតំបន់ ដែលកំពុងស្វែងរកសិទ្ធិរបស់ពួកគេ។
- ខិតខំប្រឹងប្រែងយ៉ាងណាដើម្បីជួយដល់អតិថិជន ឬ អ្នករស់នៅក្នុងតំបន់ឲ្យទទួលបានព័ត៌មានទាក់ទងនឹងថាតើមេឌីឃែរ ជំនួយវេជ្ជសាស្ត្រ កម្មវិធីសុខភាពផ្សេងទៀត ឬ កម្មវិធីសាធារណៈនឹងបង់ថ្លៃសម្រាប់សេវាឬទេ។

- រៀបចំកន្លែងស្នាក់នៅឲ្យបានសមរម្យសម្រាប់អ្នក ដែលមានពិការភាពក្នុងការទំនាក់ទំនង ឬ អ្នកដែលនិយាយភាសាផ្សេងក្រៅពីភាសាអង់គ្លេស។
- ផ្តល់នូវរាល់ព័ត៌មាន និង ការជូនដំណឹងជាភាសាសាមញ្ញ និង តាមបែប ដែលអតិថិជន ឬ អ្នករស់ក្នុងតំបន់នោះអាចយល់បាន។

គ្មានអ្នកផ្តល់សេវាណាមួយមានសិទ្ធិទាមទារ ឬ ស្នើសុំអតិថិជន ឬ អ្នករស់នៅក្នុងតំបន់នោះឲ្យលះបង់សិទ្ធិណាមួយរបស់ពួកគេ ដែលបានចុះបញ្ជីនៅក្នុងផ្នែកនេះ នៅពេលណាមួយ ឬ ដោយហេតុផលណាមួយនោះទេ ដោយរាប់បញ្ចូលទាំងលក្ខខណ្ឌនៃការផ្តួចផ្តើមសេវា ឬ ចុះកិច្ចសន្យាការរស់នៅ ដែលមានជំនួយ។

# ការបកស្រាយ និង ការអនុវត្តសិទ្ធិ

សិទ្ធិទាំងនេះត្រូវបានបង្កើតឡើង ដើម្បីជាប្រយោជន៍ដល់អតិថិជន ដែលទទួលបានសេវាថែទាំតាមគេហដ្ឋាន។ អ្នកផ្តល់សេវាថែទាំតាមផ្ទះទាំងអស់ត្រូវតែគោរពតាមសិទ្ធិទាំងនេះ។ ស្នងការក៏នឹងត្រូវអនុវត្តរឿងនេះ។ អ្នកផ្តល់សេវាថែទាំតាមផ្ទះ ឬ គេហដ្ឋានមិនអាចស្នើសុំ ឬ តម្រូវឲ្យអតិថិជនលះបង់សិទ្ធិទាំងនេះ ដើម្បីជាលក្ខខណ្ឌនៃការទទួលសេវាឡើយ។ សេចក្តីថ្លែងការណ៍អំពីសិទ្ធិនេះមិនអាចជំនួស ឬ បន្ថយនូវសិទ្ធិនិង សេរីភាពផ្សេងទៀត ដែលអាចមានទាក់ទងទៅនឹងអតិថិជន ដែលទទួលបានសេវាថែទាំតាមផ្ទះ អ្នកផ្តល់សេវាថែទាំតាមផ្ទះ ឬ អ្នកផ្តល់សេវាថែទាំតាមផ្ទះ ដែលមានអាជ្ញាប័ណ្ណ។

# ធនធាននានា

អ្នកអាចទាក់ទងអ្នកផ្តល់សេវា ដែលមានអាជ្ញាប័ណ្ណរបស់អ្នក ដូចបានបង្ហាញខាងក្រោម៖

ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ៖ ____________________

ទូរសព្ទ៖ ____________________

អ៊ីម៉ែល៖ ____________________

អាសយដ្ឋាន៖ ____________________

ឈ្មោះ និង មុខតំណែងរបស់អ្នកដែលបញ្ហា ឬ ការតវ៉ាអាចត្រូវបានយោងទៅ៖ ____________________

____________________

**រាយការណ៍ពីការរំលោភបំពាន ដែលបានសង្ស័យ ការធ្វេសប្រហែស ឬ ការកេងប្រវ័ញ្ចផ្នែកហិរញ្ញវត្ថុពីមនុស្សចាស់ ដែលងាយរងគ្រោះ៖**

មជ្ឈមណ្ឌលរាយការណ៍អំពីការរំលោភបំពានរដ្ឋ មីនីសូតា (MAARC)

ទូរសព្ទ៖ 1-844-880-1574
ចំពោះព័ត៌មានបន្ថែម៖
[ការការពារមនុស្សចាស់ ដែលងាយរងគ្រោះ និង ការរំលោភបំពានលើមនុស្សចាស់ (https://mn.gov/dhs/adult-protection/)](https://mn.gov/dhs/adult-protection/)

**សម្រាប់បណ្តឹងតវ៉ាផ្សេងទៀត** ដែលមិនត្រូវបានគេសង្ស័យថា ជាការរំលោភបំពាន ការធ្វេសប្រហែស ឬ ការកេងប្រវ័ញ្ចហិរញ្ញវត្ថុពីមនុស្សចាស់ ដែលងាយរងគ្រោះ សូមទាក់ទងមកកាន់ការិយាល័យពាក្យបណ្តឹងមន្ទីរសុខាភិបាល នៅនាយកដ្ឋានសុខាភិបាលរដ្ឋមីនីសូតា៖

នាយកដ្ឋានសុខាភិបាលរដ្ឋ មីនីសូតា

ការិយាល័យពាក្យបណ្តឹងមន្ទីរសុខាភិបាល

PO Box 64970
St. Paul, Minnesota 55164-0970
លេខទូរសព្ទ៖ 651-201-4201 or 1-800-369-7994

លេខទូរសារ៖ 651-281-9796

health.ohfc-complaints@state.mn.us
ការិយាល័យពាក្យបណ្តឹងមន្ទីរសុខាភិបាល
(https://www.health.state.mn.us/facilities/regulation/ohfc/index.html)

លេខទូរសព្ទបន្ទាន់ទីភ្នាក់ងារសុខភាពតាមផ្ទះ ដែលមានការបញ្ជាក់មេឌីឃាររបស់រដ្ឋដែលឥតគិតថ្លៃ
សម្រាប់ពាក្យបណ្តឹងតវ៉ា និង សំណួរអំពី HHAs ក្នុងតំបន់
ម៉ោងធ្វើការ៖ ច័ន្ទ ដល់ សុក្រ ម៉ោង 8:00 ព្រឹក ដល់ 4:30 រសៀល - សារអាចផ្ញើរចូលបាន 24/7
នាយកដ្ឋានសុខាភិបាលរដ្ឋ មីនីសូតា
ការិយាល័យដាក់ពាក្យបណ្តឹងមន្ទីរសុខាភិបាល
លេខទូរសព្ទ៖ 651-201-4201 or 1-800-369-7994
លេខទូរសារ៖ 651-281-9796
health.ohfc-complaints@state.mn.us
ការិយាល័យពាក្យបណ្តឹងមន្ទីរសុខាភិបាល
(https://www.health.state.mn.us/facilities/regulation/ohfc/index.html)

**ដើម្បីស្នើសុំសេវាតស៊ូមតិ** សូមទាក់ទងការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់ការថែទាំរយៈពេលវែង ឬ
ការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់សុខភាពផ្លូវចិត្តនិង ពិការភាពសម្រាប់ការលូតលាស់៖

ការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់ការថែទាំរយៈពេលវែង

PO Box 64971

St. Paul, MN 55164-0971

1-800-657-3591 or 651-431-2555
ការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់ការថែទាំរយៈពេលវែង
(http://www.mnaging.org/Advocate/OLTC.aspx)

ការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់សុខភាពផ្លូវចិត្ត និង ពិការភាពសម្រាប់ការលូតលាស់

121 7th Place

East Metro Square Building

St. Paul, MN 55101-2117

1-800-657-3506 ឬ 651-757-1800

Ombudsman.mhdd@state.mn.us
ការិយាល័យអ្នកតស៊ូមតិសាធារណៈសម្រាប់សុខភាពផ្លូវចិត្ត និង ពិការភាពសម្រាប់ការលូតលាស់
(https://mn.gov/omhdd/)

ជំនួយផ្នែកច្បាប់ពាក់កណ្ដាលរដ្ឋមីនីសូតា/មជ្ឈមណ្ឌលច្បាប់សម្រាប់ពិការភាពរដ្ឋ មីនីសូតា
(ប្រព័ន្ធការពារ និង ការតស៊ូមតិ)
430 First Avenue North, Suite 300
Minneapolis, MN 55401-1780
1-800-292-4150
mndlc@mylegalaid.org
ជំនួយផ្នែកច្បាប់ (http://mylegalaid.org/)

នាយកដ្ឋានរដ្ឋ មីនីសូតានៃសេវាមនុស្សជាតិ
(បញ្ហាការទូទាត់ប្រាក់សំណងលើការលួចបន្លំ និង ការរំលោភបំពានរបស់មេឌីខេដ)
សេវាពិនិត្យឡើងវិញលើសុចរិភាព និង ការពិនិត្យថែទាំ
PO Box 64982
St Paul, MN 55164-0982
1-800-657-3750 or 651-431-2650
DHS.SIRS@state.mn.us

ខ្សែភ្ជាប់ទៅកាន់អ្នកជំនាញសម្រាប់មនុស្សចាស់
(មជ្ឈមណ្ឌលធនធានសម្រាប់ពិការភាព និង ចាស់ជរា/ភ្នាក់ងារចាស់ជរា) ក្រុមប្រឹក្សាភិបាលរដ្ឋ មីនីសូតាស្ដីពីចាស់ជរា
PO Box 64976
St. Paul, MN 55155
1-800-333-2433
senior.linkage@state.mn.us
ខ្សែភ្ជាប់ទៅកាន់អ្នកជំនាញសម្រាប់មនុស្សចាស់ (www.SeniorLinkageLine.com)

មជ្ឈមណ្ឌលសម្រាប់ការរស់នៅឯករាជ្យ
នាយកដ្ឋានការងារនិងការអភិវឌ្ឍសេដ្ឋកិច្ច - ការរស់នៅដោយឯករាជ្យ
(https://mn.gov/deed/job-seekers/disabilities/independent/)
សូមមើលគេហទំព័រសម្រាប់ឈ្មោះ អាសយដ្ឋាន និង លេខទូរសព្ទ។

អគ្គគាហកថែទាំសុខភាពមេឌីឃែរ និង អង្គការលើកកម្ពស់គុណភាពការថែទាំផ្ដោតលើក្រុមគ្រួសារ
Livanta LLC - កម្មវិធី BFCC-QIO
10820 Guilford Road, Suite 202
Annapolis Junction, MD 20701-1105
1-888-524-9900, TTY 1-888-985-8775

អង្គការ STRATIS HEALTH
(អង្គការកែលម្អគុណភាព)
2901 Metro Drive, Suite 400
Bloomington, MN 55425-1525
ទូរសព្ទ៖ 952-854-3306
ទូរសព្ទឥតគិតថ្លៃតាមរយៈលេខ៖ 1-877-STRATIS (787-2847)
ទូរសារ៖ 952-853-8503
info@stratishealth.org

**សម្រាប់ការសាកសួរទូទៅ សូមទំនាក់ទំនង៖**

នាយកដ្ឋានសុខាភិបាលរដ្ឋមីនីសូតា

ផ្នែកបទបញ្ជាត្រួតពិនិត្យសុខភាព
85 E. 7th Place
PO Box 64970
St. Paul, MN 55164-0970
651-201-4101
health.fpc-web@health.state.mn.us
នាយកដ្ឋានសុខាភិបាលនៃរដ្ឋ មីនីសូតា (www.health.state.mn.us)

ដើម្បីត្រូវបានប្រើដោយអ្នកផ្តល់សេវាដែលបានបញ្ជាក់ដោយ Medicare ក្នុងច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋមីនីសូតាផ្នែកទី 144A.44 ផ្នែករង 1 និង 144A.441 លើកលែងតែភាសាដែលបោះពុម្ពជាអក្សរដិតដែលតំណាងឱ្យសិទ្ធិអ្នកប្រើប្រាស់បន្ថែមក្រោមច្បាប់សហព័ន្ធលេខ 42CFR 484.50។ សិទ្ធិទាំងនេះទាក់ទងនឹងអតិថិជន ដែលទទួលបានសេវាថែទាំតាមគេហដ្ឋានពីភ្នាក់ងារ ដែលមានលិខិតបញ្ជាក់មេឌីឃារ ដែលជាអ្នកផ្តល់សេវាថែទាំតាមផ្ទះដែលមានអាជ្ញាប័ណ្ណដែលផ្តល់ការថែទាំដល់អតិថិជនដែលរស់នៅត្រូវការជំនួយដូចដែលបានកំណត់ដោយ 144G ។

អ្នកផ្តល់សេវាថែទាំតាមគេហដ្ឋានត្រូវផ្តល់ជូនអតិថិជននូវលិខិតជូនដំណឹងអំពីសិទ្ធិនានាមុនពេលកាលបរិច្ឆេទ ដែលផ្តល់សេវាត្រូវបានផ្តល់ឡើងជាលើកដំបូងដល់អតិថិជននោះ។ អ្នកផ្តល់សេវាត្រូវខិតខំប្រឹងប្រែងឲ្យបានសមស្រប ដើម្បីផ្តល់សេចក្តីជូនដំណឹងអំពីសិទ្ធិដល់អតិថិជន ឬ តំណាងអតិថិជនដោយប្រើភាសាមួយ ដែលអតិថិជនឬ តំណាងអតិថិជនអាចយល់បាន។

នាយកដ្ឋានសុខាភិបាលរដ្ឋ មីនីសូតា
ផ្នែកបទបញ្ជាត្រួតពិនិត្យសុខភាព
P.O. Box 64900
St. Paul, Minnesota 55164-0900
651-201-4101
health.fpc-licensing@state.mn.us

បានកែសម្រួលខែវិច្ឆិកាឆ្នាំ 2019

*ដើម្បីទទួលបានព័ត៌មាននេះក្នុងទម្រង់ទ្រាយផ្សេង សូមទូរសព្ទទៅ៖ 651-201-4101 ។*